# អនុក្រឹត្យលេខ ១០៧ អនក្រ.បក ចុះថ្ងៃទី៣០/០៨/២០១០ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបរិស្ថាននិងសុខភាព

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៧អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៦៧អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសុខាភិបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០០០

សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានបង្កើតគណៈកម្មាធិការជាតិបរិស្ថាននិងសុខភាព ដែលសរសេរអក្សរកាត់ថា គ.ជ.ប.ស. ។

គ.ជ.ប.ស. ជាយន្តការសម្របសម្រួលថ្នាក់ជាតិ និងពិគ្រោះយោបល់លើបញ្ហាបរិស្ថានដែលប៉ះពាល់ដល់សុខភាពសាធារណៈ ។

## ជំពូកទី២

## សមាសភាពរបស់ គ.ជ.ប.ស.

មាត្រា ២.-

គ.ជ.ប.ស មានសមាសភាពដូចតទៅ:

- រដ្ឋមន្ត្រី ក្រសួងសុខាភិបាល ប្រធាន
- រដ្ឋលេខាធិការ ក្រសួងបរិស្ថាន ១រូប អនុប្រធាន
- រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ ១រូប អនុប្រធាន
- រដ្ឋលេខាធិការ ក្រសួងសុខាភិបាល ១រូប អនុប្រធាន អចិន្ត្រៃយ៍
- រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងការពារជាតិ ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប សមាជិក

- រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងផែនការ ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងធនធានទឹក និង ឧតុនិយម ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងព័ត៌មាន ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងសាធារណៈការ និង ដឹកជញ្ជូន ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងធម្មការ និង កិច្ចការសាសនា ១រូប សមាជិក
- រដ្ឋលេខាធិការ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សមាជិក ។

សមាសភាពជាក់ស្តែងរបស់ គ.ជ.ប.ស. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី៣

## ភារកិច្ចរបស់ គ.ជ.ប.ស.

### មាត្រា ៣.-

គ.ជ.ប.ស. មានភារកិច្ចដូចតទៅ:

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិនៃបរិស្ថាន និងសុខភាព ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- ជម្រុញ និងតាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិនៃបរិស្ថាន និងសុខភាពដើម្បីលើកកម្ពស់ការការពារបរិស្ថាននិងសុខភាពរបស់ប្រជាពលរដ្ឋ ដែលជាកត្តាចម្បងសម្រាប់ការអភិវឌ្ឍធនធានមនុស្ស វឌ្ឍនភាពសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកប ដោយចីរភាព
- បង្កើនកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាស្ថាប័ននៅគ្រប់ថ្នាក់ គ្រប់ផ្នែក ជាពិសេសប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាសហគមន៍អន្តរជាតិលើវិស័យបរិស្ថាននិងសុខភាព
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារ ស្តីពីបរិស្ថាននិងសុខភាពជូនរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

## ជំពូកទី៤

## ការប្រព្រឹត្តទៅរបស់ គ.ជ.ប.ស.

មាត្រា ៤.-

សមាជិក គ.ជ.ប.ស. ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

គ.ជ.ប.ស. មានសិទ្ធប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាល ។

មាត្រា ៥.-

គ.ជ.ប.ស. មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ដោយឡែក នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងសុខភិបាល។

គ.ជ.ប.ស. អាចទទួលធនធានផ្គត់ផ្គង់ដោយមូលនិធិជាហិរញ្ញប្បទាន ដែលបានមកពីដៃគូអភិវឌ្ឍ និងពីប្រភពផ្សេងៗសម្រាប់បំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ ។

គ.ជ.ប.ស. មានក្រុមការងារបច្ចេកទេសមួយចំនួនតាមការចាំបាច់ ។ សមាសភាពនិងតួនាទីភារកិច្ចរបស់ក្រុមការងារបច្ចេកទេស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប.ស. ។

គ.ជ.ប.ស. មាននាយកដ្ឋានការងារសុខាភិបាលនៃក្រសួងសុខាភិបាលជាលេខាធិការដ្ឋាន ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

មាត្រា ៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកនិរាករណ៍ ។

មាត្រា ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា ២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- រាជកិច្ច